# វាក្យសព្ទដំណឹងល្អរបស់ខ្ញុំ

សូមរកមើលវាក្យសព្ទ និងឃ្លាទាំងនេះនៅក្នុងទស្សនាវដ្ដី *ប្រិយមិត្ត* ច្បាប់នេះ !

## ការនិមិត្តដំបូង

ការនិមិត្តដំបូង គឺនៅពេលដែលព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទបានយាងទៅជួប យ៉ូសែប ស្ម៊ីធ បន្ទាប់ពីលោកបានអធិស្ឋាន ។ លោកចង់ដឹងថា តើលោកគួរតែចូលរួមក្នុងព្រះវិហារមួយណា ។ ទ្រង់ទាំងទ្វេបានមានបន្ទូលប្រាប់យ៉ូសែបថា លោកនឹងជួយរៀបចំសាសនាចក្រពិតរបស់ព្រះយេស៊ូវគ្រីស្ទនៅលើផែនដីនេះ ។



## ព្រៃពិសិដ្ឋ

ព្រៃពិសិដ្ឋ គឺជាកន្លែងដែល យ៉ូសែប ស្ម៊ីធ មានការនិមិត្តដំបូង ។ វាស្ថិតនៅក្នុងព្រៃក្បែរផ្ទះរបស់ យ៉ូសែប នៅឯភូមិប៉ាលម៉ៃរ៉ា រដ្ឋញូវយ៉ក ស.រ.អា. ។



## ការស្ដារឡើងវិញ

ដើម្បីស្ដារអ្វីមួយឡើងវិញមានន័យថា ធ្វើឲ្យអ្វីមួយនោះត្រឡប់ទៅកាន់សភាពដើមវិញ ។ ការស្ដារឡើងវិញ គឺជាអ្វីដែលយើងហៅថា ព្រះយេស៊ូវគ្រីស្ទនាំដំណឹងល្អដ៏ពិតរបស់ទ្រង់ត្រឡប់មកកាន់ផែនដីវិញ ។ ការស្ដារឡើងវិញបានចាប់ផ្ដើមនៅពេលដែល យ៉ូសែប ស្ម៊ីធ មានការនិមិត្តដំបូង ។ ប្រធាន រ័សុល អិម ណិលសុន នៅតែទទួលវិវរណៈសម្រាប់សាសនាចក្រ ក្នុងនាមជាព្យាការីរបស់យើង ។ ការណ៏នេះមានន័យថា ការស្ដារឡើងវិញនៅតែបន្តនាសព្វថ្ងៃនេះ !

## វិវរណៈ

វិវរណៈ គឺជារបៀបដែលព្រះវរបិតាសួគ៌មានបន្ទូលមកកាន់យើង ។ យើងអាចទទួលបានវិវរណៈ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ ទ្រង់អាចនាំយកនូវអារម្មណ៍ទាំងឡាយមកកាន់ដួងចិត្តរបស់យើង និងការបំផុសគំនិតទាំងឡាយមកកាន់គំនិតរបស់យើង ។

រូបភាពដោយ ជេស៊ី ប៊ើក